**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧ ០១៦ ១៤៧ ប្រ.ក

# ប្រកាស
## ស្ដីពី
## សមាជិកភាពប្រព័ន្ធ FAST និង ប្រព័ន្ធ Central Shared Switch

៚៚៚

## ទេសាភិបាល ធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/៤១៧ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៥ ស្ដីពីការតែងតាំង **ឯកឧត្តម ជា ចាន់តូ** ជាអគ្គទេសាភិបាល ធនាគារជាតិនៃកម្ពុជាជាថ្មី មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មមាត្រា ១៤ និងមាត្រា ៥៧ នៃច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៦/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៥/០៣០ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់
- យោងស្មារតីនៃអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៦

## សម្រេច

**ប្រការ ១.-**

ប្រកាសនេះ មានគោលបំណងតម្រូវឲ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុចូលរួមជាសមាជិកប្រព័ន្ធ FAST និង ប្រព័ន្ធ Central Shared Switch ជាកាតព្វកិច្ច ។



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

**ប្រការ ២.-**

ប្រកាសនេះ មានគោលដៅជំរុញការទូទាត់រាយឲ្យកាន់តែ ងាយស្រួល រហ័ស ប្រសិទ្ធភាព សុវត្ថិភាព និងជឿទុកចិត្តបាន ដើម្បីលើកកម្ពស់ការអភិវឌ្ឍវិស័យធនាគារនិង ហិរញ្ញវត្ថុ និង សេដ្ឋកិច្ចជាតិ ។

**ប្រការ ៣.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះ ធនាគារពាណិជ្ជ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទទួលប្រាក់បញ្ញើ តទៅនេះហៅថា "គ្រឹះស្ថាន" ។

**ប្រការ ៤.-**

ប្រព័ន្ធ FAST (Fast And Secure Transfers) គឺជាប្រព័ន្ធទូទាត់សងប្រាក់រាយ ដែល ដំណើរការប្រតិបត្តិការទូទាត់សងប្រាក់រវាងគ្រឹះស្ថានជាសមាជិក ។ ប្រតិបត្តិការទូទាត់សងប្រាក់ តាមរយៈប្រព័ន្ធនេះ ធ្វើឡើងជាប្រាក់រៀល និងអនុញ្ញាតឲ្យអតិថិជនរបស់គ្រឹះស្ថានជាសមាជិកទទួល បាននូវមូលនិធិភ្លាមៗ ។

ប្រព័ន្ធ Central Shared Switch គឺជាប្រព័ន្ធកណ្តាលសម្រាប់ ភ្ជាប់បណ្តាញម៉ាស៊ីន ដកប្រាក់ស្វ័យប្រវត្តិ (ATM - Automated Teller Machine) និងម៉ាស៊ីនឆូតកាត (EFTPOS - Electronic Fund Transfer Point of Sale) របស់គ្រឹះស្ថានជាសមាជិក ។

**ប្រការ ៥.-**

ប្រតិបត្តិការទាក់ទងប្រព័ន្ធ FAST និង ប្រព័ន្ធ Central Shared Switch មានចែងក្នុង វិធាន និងនីតិវិធីដោយឡែក ។

**ប្រការ ៦.-**

គ្រឹះស្ថានជាសមាជិក មានកាតព្វកិច្ចរៀបចំប្រព័ន្ធធនាគារស្នូល និងហេដ្ឋារចនាសម្ព័ន្ធ សមស្របសម្រាប់តភ្ជាប់ជាមួយប្រព័ន្ធ FAST និង ប្រព័ន្ធ Central Shared Switch ។

**ប្រការ ៧.-**

គ្រឹះស្ថាន មានកាតព្វកិច្ចចូលរួមជាសមាជិកនៅក្នុងប្រព័ន្ធ FAST ឲ្យបានមុនថ្ងៃទី០១ ខែមករា ឆ្នាំ២០១៧ និងជាសមាជិកនៅក្នុងប្រព័ន្ធ Central Shared Switch ឲ្យបានមុនថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ ជាកំហិត ។

**ប្រការ ៨.-**

ការខកខានមិនបានចូលរួមតាមខ្លឹមសារនៃប្រកាសនេះ ត្រូវទទួលរងទណ្ឌកម្មដូចមានចែងក្នុងមាត្រាទី៥២ នៃច្បាប់ស្ដីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

**ប្រការ ៩.-**

អគ្គលេខាធិការ អគ្គបេឡា អគ្គនាយកបច្ចេកទេស អគ្គនាយកត្រួតពិនិត្យ អគ្គពិនិត្យ ប្រធាននាយកដ្ឋាន អង្គភាពក្រោមឱវាទ និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តយ៉ាងម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ១០.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ២០១៦

**ទេសាភិបាល**

ជា.ចាន់តូ

**<u>កន្លែងទទួល៖</u>**
- ដូចមានចែងក្នុងប្រការ ៩ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**<u>ចម្លងជូន៖</u>**
- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្ដីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្ដីការគណៈរដ្ឋមន្ត្រី
  "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"